# កម្មវិធីជំរំយុវជន

## ១. សេចក្តីផ្តើម

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា សូមប្រកាសជ្រើសរើសយុវជនចំនួន ៥០នាក់ ដើម្បីចូលរួមកម្មវិធីជំរំយុវជនស្តីពី “សេរីភាពមូលដ្ឋានដើម្បីអ្នកទាំងអស់គ្នា” ដែលមានរយៈពេលចំនួន៤ថ្ងៃ។

សេរីភាពមូលដ្ឋានរួមមាន សេរីភាពខាងការបញ្ចេញមតិ ជួបប្រជុំ និងសមាគម គឺជាសិទ្ធិមនុស្សមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ និងធានាជាសាកលដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដោយឡែក ប្រទេសកម្ពុជាបានទទួលស្គាល់ និងធានានូវការអនុវត្តសេរីភាពមូលដ្ឋានតាមរយៈការផ្តល់សច្ចាប័នលើអនុសញ្ញា និងកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្ស និងបានដាក់បញ្ចូលខ្លឹមសារនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិទៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួនថែមទៀតផង។

កម្មវិធីនេះជាផ្នែកមួយនៃគម្រោងការពារសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី និងធនធានធម្មជាតិ ដែលមានគោលបំណងដូចតទៅ៖

- ដើម្បីផ្តល់ចំណេះដឹងបន្ថែមអំពីសេរីភាពមូលដ្ឋានរួមមាន សេរីភាពខាងការបញ្ចេញមតិ ជួបប្រជុំ និងសមាគម ដែលធានាដែលត្រូវបានធានាដោយក្របខ័ណ្ឌច្បាប់ជាតិ និងអន្តរជាតិ សិទ្ធិដីធ្លី និងធនធានធម្មជាតិ និងគោលគំនិតចំពោះសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។
- ដើម្បីបញ្ជ្រាបអំពីតួនាទីរបស់យុវជនក្នុងសង្គមប្រជាធិបតេយ្យ។

## ២. លក្ខខណ្ឌចូលរួម

- អាយុចាប់ពី ១៨ ដល់ ៣៥ ឆ្នាំ។
- មិនធ្លាប់ចូលរួមជំរំយុវជនរបស់ ម.ស.ម.ក ពីមុនមកទេ។
- ការប្តេជ្ញាចិត្តក្នុងការចូលរួមក្នុងកម្មវិធីជំរុំយុវជនឱ្យបានពេញលេញ។
- យុវជនដែលជាស្ត្រី អ្នកស្រឡាញ់ភេទដូចគ្នា ជនជាតិដើមភាគតិច ជនមានពិការភាពត្រូវបានលើកទឹកចិត្តឱ្យដាក់ពាក្យ។

## ៣. កាលបរិច្ឆេទ និងទីកន្លែង

យុវជន៥០នាក់ នឹងត្រូវបានជ្រើសរើសចូលរួមក្នុងកម្មវិធីជំរំយុវជន ដោយផ្អែកលើចម្លើយដែលបានបំពេញនៅក្នុងកម្រងសំណួរដាក់ពាក្យចូលរួម និងវាយតម្លៃលើគុណសម្បត្តិរបស់បេក្ខជនបំពេញពាក្យចូលរួម។

កម្មវិធីជំរំយុវជននេះ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥-២៨ ខែមិថុនា ឆ្នាំ២០២៤ ។ ទីកន្លែងដាក់លាក់នឹងជូនដំណឹងនៅពេលក្រោយ។

## ៤. របៀបដាក់ពាក្យ

យុវជនដែលមានចំណាប់អារម្មណ៍ សូមចុះឈ្មោះ និងបំពេញកម្រងសំណួរតាមរយៈតំណភ្ជាប់នេះ។

- ការចុះឈ្មោះ និងបំពេញពាក្យចូលរួមធ្វើឡើងដោយឥតគិតថ្លៃ។
- ថ្ងៃផុតកំណត់៖ **ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង ៥:៣០ នាទីល្ងាច។**

**សំគាល់៖** ម.ស.ម.ក នឹងជូនដំណឹងអំពីលទ្ធផលដល់យុវជនដែលត្រូវបានជ្រើសរើសចូលរួមកម្មវិធីជំរំយុវជននេះ បន្ទាប់ពីកាលបរិច្ឆេទជ្រើសរើសត្រូវផុតកំណត់ ដោយជូនដំណឹងផ្ទាល់ទៅកាន់អ្នកដែលត្រូវបានជ្រើសរើសតែប៉ុណ្ណោះ។ ម.ស.ម.ក នឹងផ្តល់ជូននូវលិខិតបញ្ជាក់ពីការចូលរួមកម្មវិធីនេះដល់យុវជនដែលបានចូលរួមពេញលេញរហូតដល់ចប់កម្មវិធី។

## ៥. ការស្នាក់នៅ និងការធ្វើដំណើរ

ម.ស.ម.ក នឹងចេញថ្លៃអាហារ ការស្នាក់នៅ និងការធ្វើដំណើរក្នុងអំឡុងពេលកម្មវិធីនេះដល់យុវជនមកពីបណ្តារាជធានី/ខេត្ត ស្របតាមគោលការណ៍របស់ ម.ស.ម.ក ។ សម្រាប់ព័ត៌មានលម្អិតនឹងមានចែងក្នុងកំណត់សម្គាល់រដ្ឋបាលនាពេលក្រោយសម្រាប់បេក្ខជនដែលត្រូវបានជ្រើសរើស។

## ៦. ព័ត៌មានបន្ថែម

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមរយៈអ៊ីម៉ែល info@cchrcambodia.org ឬលេខទូរស័ព្ទ៖ ០២៣ ៧២៦ ៩០១ ជារៀងរាល់ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង ៧៖៣០ នាទីព្រឹក ដល់ម៉ោង ៥៖៣០នាទីល្ងាច៕

---- x ----